ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា

លេខ : ១២៥៥/១៦ អ គ រ

រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៦

**ជម្រាបមក**

**អស់លោក លោកស្រីប្រធាននាយកដ្ឋាន សាខានិងការិយាល័យគយនិងរដ្ឋាករ**

ការប្រមូលពន្ធនិងអាករក្នុងខែគិតត្រឹមថ្ងៃទី១៨ កក្កដា នេះបានត្រឹមតែ ៣៣០ប៊ីលានរៀល គឺទាបជាងខែមុន ប្រមាណ១២.២ប៊ីលានរៀល (ចំណូលក្នុងខែត្រឹមថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០១៦ បាន៣៤២.២ប៊ីលានរៀល)។ ស្ថានភាពចំណូលទាបក្នុងខែនេះ គឺជាការបារម្ភមួយក្នុងការអនុវត្តផែនការចំណូលឱ្យបានលទ្ធផលល្អតាមការកំណត់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ ជាការពិត មានកត្តារដូវកាលដែលជះឥទ្ធិពលមិនល្អខ្លះដល់ការប្រមូលចំណូល ក៏ប៉ុន្តែលទ្ធផលប្រមូលចំណូលប្រចាំថ្ងៃរយៈពេល៣-៤ថ្ងៃចុងក្រោយនេះ រឹតតែជះឥទ្ធិពលមិនល្អដល់ការប្រមូលចំណូលពន្ធអាករសរុបប្រចាំខែនេះ (ថ្ងៃទី១៦ ខែកក្កដាបាន២០.១ប៊ីលានរៀល, ថ្ងៃច័ន្ទទី១៨ ខែកក្កដា បាន២០.២ប៊ីលានរៀលតែប៉ុណ្ណោះ)។ ដោយពេលវេលានៅសល់ប្រមាណតែ១១ថ្ងៃទៀតប៉ុណ្ណោះក្នុងខែនេះ (មិនគិតថ្ងៃអាទិត្យ) ខ្ញុំសូមក្រើនរំលឹក និងធ្វើការណែនាំដល់អស់លោក លោកស្រីប្រធានអង្គភាពគយ និងរដ្ឋាករពាក់ព័ន្ធទាំងអស់ដូចខាងក្រោម÷

**១. ត្រូវណែនាំដល់ម្ចាស់ទំនិញឬតំណាងឱ្យប្រកាសបានត្រឹមត្រូវតាមបរិមាណ និងយថាប្រភេទទំនិញ**

**២. ត្រូវណែនាំមន្ត្រីនិងភ្នាក់ងារគយរដ្ឋាករឱ្យពង្រឹងការត្រួតពិនិត្យឯកសារ និងទំនិញដើម្បីគណនាពន្ធនិងអាករឱ្យបានត្រឹមត្រូវ**

**៣. នាយកដ្ឋានបង្ការ និងបង្ក្រាបបទល្មើស និង សាខាគយ និងរដ្ឋាកររាជធានីភ្នំពេញត្រូវសកម្មក្នុងការទប់ស្កាត់ និងបង្ក្រាបអំពើរត់គេចពន្ធ ជាពិសេសលើក្រុមទំនិញដែលជាមុខសញ្ញាគេចវេះពន្ធ (សូមរំលឹកអំពីមតិណែនាំរបស់ ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដែលបានលើកឡើងក្នុងកិច្ចប្រជុំបូកសរុបការងារគយនិងរដ្ឋាករប្រចាំឆមាសទី១ ឆ្នាំ២០១៦ ដែលបានប្រព្រឹត្តទៅនៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៦)**

**៤. ក្រុមពង្រឹងអនុលោមភាពត្រូវឃ្លាំមើល និងចាត់វិធានការក្រោយទទួលបានព័ត៌មានច្បាស់លាស់ពីបណ្តាញ។**

ក្រោយទទួលបានការណែនាំនេះ សូមអស់លោក លោកស្រីប្រធាន ចាត់ចែងអនុវត្តជាបន្ទាន់ និងដោយសកម្មប្រកបដោយស្មារតីទទួលខុសត្រូវនិងឱ្យមានប្រសិទ្ធភាពខ្ពស់។

សូមអស់លោក លោកស្រី ប្រធានអង្គភាពគយ និង រដ្ឋាករទាំងអស់ទទួលនូវការស្រឡាញ់រាប់អានពីខ្ញុំ

**អគ្គនាយក**

**អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា**

**បណ្ឌិត គុណ-ញឹម**

អាសយដ្ឋាន: លេខ ៦-៨ មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទ / ទូរសារ: (៨៥៥-២៣) ២១៤ ០៦៥ / ៧២៥ ១៨៧ / ២១២ ៥៩៧ / E-mail: info-pru@customs.gov.kh